ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ

លេខ: ០៤៧/១៨ សណម.

# សេចក្តីជូនដំណឹង

## ស្តីពី ការកែសម្រួលខ្សែរត់រថយន្តក្រុងចាស់ និងបន្ថែមបណ្តាញខ្សែរត់ថ្មី របស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) រាជធានីភ្នំពេញ

រដ្ឋបាលរាជធានីភ្នំពេញ សូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់ឱ្យបានជ្រាបថា ដើម្បីពង្រីកវិសាលភាពនៃការបម្រើសេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុង ជូនបងប្អូនប្រជាពលរដ្ឋស្របពេលរថយន្តក្រុងដែលជាជំនួយរបស់រដ្ឋាភិបាលជប៉ុននឹងមកដល់គ្រប់ចំនួន៨០គ្រឿង នៅចុងឆ្នាំ២០១៨ ខាងមុខនេះ រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) នៃរដ្ឋបាលរាជធានីភ្នំពេញ បានធ្វើការកែសម្រួលខ្សែរត់ចាស់ និងបន្ថែមបណ្តាញខ្សែរត់រថយន្តក្រុងថ្មី ហើយគ្រោងនឹងដាក់ឱ្យដំណើរការជូនបងប្អូនប្រជាពលរដ្ឋ ចាប់ពីថ្ងៃទី០១ ខែតុលាឆ្នាំ២០១៨ ដូចខាងក្រោម៖

**I. ការកែសម្រួលខ្សែរត់ចាស់**

1. ខ្សែទី១: ដែលពីមុនរត់ចេញពីគីឡូម៉ែត្រលេខ៩ ផ្លូវជាតិលេខ៥ ដល់ចំណតបឹងឈូក ផ្លូវជាតិ លេខ១ ត្រូវបានកែសម្រួលជាពីរ៖
   - ខ្សែទី១A: ចេញពីផ្សារព្រែកព្នៅ ផ្លូវជាតិលេខ៥ ផ្លូវព្រះមុនីវង្ស ស្ពានព្រះមុនីវង្ស ដល់ចំណតរថយន្តច្បារអំពៅ ។
   - ខ្សែទី១B : ចេញពីចំណតរថយន្តច្បារអំពៅ តាមផ្លូវជាតិលេខ១ ដល់ផ្សារគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។
2. ខ្សែទី២: ដែលពីមុនរត់ចេញពីចំណតផ្សារអ៊ីអន២ (សែនសុខ) ដល់ក្រុងតាខ្មៅ ត្រូវបានកែសម្រួលឱ្យរត់ចេញពីរង្វង់មូលកូចកាណុង ផ្លូវលេខ៤៧ វត្តភ្នំ មហាវិថីព្រះនរោត្តម ស្ពានអាកាសក្បាលថ្នល់ ផ្លូវជាតិលេខ២ ដល់ស្ពានព្រែកសំរោង ក្រុងតាខ្មៅ ខេត្តកណ្តាល ។
3. ខ្សែទី៤: ត្រូវបានកែសម្រួល និងបន្ថែមថ្មីដូចខាងក្រោម៖
   - ខ្សែទី៤B : ត្រូវបានបន្លាយពីតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ឱ្យទៅដល់ទីក្រុងពាណិជ្ជកម្ម ចេងឌូបាយ៉ កម្ពុជា-ចិន ស្រុកអង្គស្នួល ខេត្តកណ្តាល ។
   - ខ្សែទី៤C : រត់ចេញពីចំណតសួនឫស្សីកែវ ផ្លូវជាតិលេខ៥ រង្វង់មូលកូចកាណុង ផ្លូវលេខ៤៧ វត្តភ្នំ មហាវិថីនរោត្តម ផ្លូវលេខ១៣០ ផ្សារធំថ្មី មហាវិថីហ្សាលដឺហ្គោល ស្តុបនាងគង្ហីង ស្តុបអាងទឹកអូឡាំពិក ផ្លូវមុនីរ៉េត ផ្សារដើមគរ ស្ពានអាកាសស្ទឹងមានជ័យ ច្រមុះជ្រូក ស្ទឹងមានជ័យ កាត់តាមផ្លូវ២១៧ ដល់រង្វង់មូលដីក្រហម (កូរស្រូវ) ។
4. ខ្សែទី៥ : ដែលពីមុនរត់ចេញពីផ្សារអ៊ីអន២ ដល់ផ្សារអ៊ីអន១ ត្រូវបានបន្លាយឱ្យរត់ទៅដល់ស្ថានីយ៍ចំណតរថយន្តក្រុង នៅភូមិព្រែកតាវ័ន្ត សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វារ ។

៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

5. ខ្សែទី៦ ត្រូវបានកែសម្រួលឱ្យរត់ចេញពីរង្វង់មូលកូចកាណុង កាត់ស្ពានជ្រោយចង្វារ ផ្លូវជាតិលេខ៦ បត់ឆ្វេងតាមវិថីឈ្នះឈ្នះ ដល់ស្ថានីយ៍រថយន្តក្រុង នៅភូមិព្រែកតាវ័ន្ត សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ។

6. ខ្សែទី៧ : រត់ចេញពីចំណតតឺឡាប្រ៉េលេខ៩ ផ្លូវជាតិលេខ៥ បត់ឆ្វេងតាមផ្លូវ៥៩៨ កាត់ក្រោមស្ពានអាកាស៧មករា ផ្លូវ២៧១ កាត់ស្ពានអាកាស ស្ទឹងមានជ័យ ផ្លូវ២៧១ ស្ពានព្រះមុនីវង្ស ដល់ចំណតបឹងឈូក ។

7. ខ្សែទី៨ : ចេញពីរង្វង់មូលកូចកាណុង ផ្លូវលេខ៧០ ស្តុបរង់តែនទួលគោក ស្តុបកាំកូស៊ីធី ផ្លូវឧកញ៉ាម៉ុងឬទ្ធី ផ្លូវសម្តេច ជា ស៊ីម បត់ឆ្វេងតាមផ្លូវឧកញ៉ា ទ្រី ហេង ផ្លូវសហព័ន្ធរុស្ស៊ី បត់ឆ្វេងឆ្ពោះទៅផ្សារស៊ិនជូវ៉ីថ្លាហ្វា ។

II. **បណ្តាញខ្សែរត់ដែលត្រូវបន្ថែមថ្មី**

8. ខ្សែទី១០ : ចេញពីផ្សារស៊ិនជូវ៉ីថ្លាហ្វា បត់ឆ្វេងតាមស្តុប២០០៤ ផ្លូវ២០០៤ ផ្លូវសឡា ផ្លូវចោមចៅ ផ្លូវ២១៧ ផ្លូវ៣៧១ ស្ពានព្រះមុនីវង្ស ដល់ចំណតបឹងឈូក ។

9. ខ្សែទី១១ : ចេញពីវត្តស្លែង ផ្លូវព្រៃវែងពងទឹក បត់ឆ្វេងតាមផ្លូវព្រែស បត់ឆ្វេងតាមផ្លូវ២១៧ ដល់ច្រមុះជ្រូកស្ទឹងមានជ័យ (វីលជុំ) ។

10. ខ្សែទី១២ : (រត់ជារង្វង់) ចេញពីរាជាយស្ម័យយាន មហាវិថីសហព័ន្ធរុស្ស៊ី បត់ឆ្វេងតាមផ្លូវនេរុតាមផ្លូវព្រះសីហនុ បត់ស្តាំតាមផ្លូវ១៦៣ បត់ឆ្វេងតាមផ្លូវ៣៦០ បត់ឆ្វេងតាមផ្លូវត្រសក់ផ្អែម ផ្សារធំថ្មី បត់ឆ្វេងតាមផ្លូវឆ្ពោះព្រះអង្គឌួង រាជាយស្ម័យយាន ។

11. ខ្សែទី១៣ : ចេញពីរង្វង់មូលកូចកាណុង ផ្លូវលេខ៧០ ផ្លូវបឹងកក់ ស្តុបក្តាន់ពីរ ផ្លូវ១៦៩ ស្តុបនាងគង្ហីង រង្វង់មូលសំពៅមាស ផ្លូវ១៦៣ ដល់រង្វង់មូលផ្សារដើមថ្កូវ(វីលជុំ) ។

ទទួលបានសេចក្តីជូនដំណឹងនេះ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌទាំង១២ អង្គភាពពាក់ព័ន្ធ និងបងប្អូនប្រជាពលរដ្ឋទាំងអស់ ចូលរួមអនុវត្តសេចក្តីជូនដំណឹងនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃព្រហ ៤កើត ខែ ភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០១៨

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសាធារណការ និងដឹកជញ្ជូន

"ដើម្បីជូនជ្រាប"
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
- មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ
- សាលាខណ្ឌទាំង១២
- គ្រប់បណ្តាញសារព័ត៌មាន

"ដើម្បីជួយផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ

# ផែនទីតម្រុយផ្លូវរត់រថយន្តក្រុងឆ្នាំ ២០១៨




**កំណត់សំគាល់**

- ខ្សែទី១A: ផ្សារព្រែកព្នៅ - ចំណតច្បារអំពៅ ប្រវែង ១៩គ.ម
- ខ្សែទី១B: ចំណតច្បារអំពៅ - ផ្សារគគីរ ប្រវែង ១៨គ.ម
- ខ្សែទី២: រង្វង់មូលគូចកាណាង - រង្វង់មូលតាខ្មៅ - ស្ពានព្រែកសំរោង ប្រវែង ១៨គ.ម
- ខ្សែទី៣: ចំណតសួនច្បារឫស្សីកែវ - បុរីសន្តិភាព២ ប្រវែង ២៣.១គ.ម
- ខ្សែទី៤A: ចំណតសួនច្បារឫស្សីកែវ - បុរីសន្តិភាព២ ប្រវែង ២០.១២គ.ម
- ខ្សែទី៤B: ចំណតសួនច្បារឫស្សីកែវ - មជ្ឈមណ្ឌលពាណិជ្ជកម្ម កម្ពុជា-ចិន(អង្គស្នួល) ប្រវែង២៨.៧គ.ម
- ខ្សែទី៤C: ចំណតសួនច្បារឫស្សីកែវ - រង្វង់មូលជីក្រហម ប្រវែង ២០.៥គ.ម
- ខ្សែទី៥: ស្ថានីយរថយន្តក្រុងព្រែកព្នៅ - ផ្សារអ៊ីអន២ - ផ្សារអ៊ីអន១ ប្រវែង ២៣.៤គ.ម
- ខ្សែទី៦: រង្វង់មូលគូចកាណាង - ស្ថានីយរថយន្តក្រុងព្រែកព្នៅ ប្រវែង ២០.២គ.ម
- ខ្សែទី៧: ចំណតគីឡូម៉ែត្រលេខ៩ - ចំណតបឹងឈូក ប្រវែង ២១.៧គ.ម
- ខ្សែទី៨: រង្វង់មូលគូចកាណាង - ផ្សារស៊ិនជូវ៉ថ្លាហ្សា ប្រវែង ១១.២គ.ម
- ខ្សែទី៩: បុរីសន្តិភាព២ - តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ប្រវែង ១៩.៥គ.ម
- ខ្សែទី១០: ផ្សារស៊ិនជូវ៉ថ្លាហ្សា - ចំណតបឹងឈូក ប្រវែង ១៧.៣គ.ម
- ខ្សែទី១១: ត្រ្ពស្លែង - ច្រមុះជ្រូកស្ទឹងមានជ័យ ប្រវែង ១៤គ.ម
- ខ្សែទី១២: រាជាយស្វ័យយានកម្ពុជា(ខ្សែរត់ជារង្វង់វៃលជុំ) តាមផ្លូវសហព័ន្ធរុស្ស៊ី នេរុ ព្រះសីហនុ ផ្លូវ៣៦០ ផ្លូវ១៦៣ ស្តុបបឹងកេងកង ត្រសក់ផ្អែម/ប៉ាស្ទ័រ ផ្លូវត្បោះព្រះអង្គឌួង ប្រវែង ៨.៩ គ.ម
- ខ្សែទី១៣: រង្វង់មូលគូចកាណាង - រង្វង់មូលផ្សារដើមថ្កូវ ប្រវែង៧.៨គ.ម

ថ្ងៃ... ខែ កត្តិក ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ កញ្ញា ឆ្នាំ ២០១៨
**អភិបាលរដ្ឋាករ**

**អ៊ាន_សុឃឹម**

បានឃើញ និងបញ្ជូនមក ឯកឧត្តមអភិបាល
នៃគណៈអភិបាលរាជធានីភ្នំពេញមេត្តាពិនិត្យ និងសំរេច
**ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ**

**សាំ ពិសិដ្ឋ**

**បានឃើញ និងឯកភាព**
ថ្ងៃ... ខែ កត្តិក ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ កញ្ញា ឆ្នាំ ២០១៨
**អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**